ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.៩៨០ ហិកតា ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច ស្ថិតនៅក្នុងភូមិសាស្ត្រស្រុក សង្គមថ្មី និងស្រុករវៀង ខេត្តព្រះវិហារ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៥.៩៤០ ( ប្រាំពាន់ប្រាំបួនរយសែសិប) ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកសង្គមថ្មី និងស្រុករវៀង ខេត្តព្រះវិហារ ក្រោមល័ក្ខខ័ណ្ឌសម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម (កៅស៊ូ) ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១១៥៣ សជណ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

# ផែនទីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឆាយណា ហ្គ្រែនខស (ខេមបូឌា) អ៊ិនវេសមេន ស្ថិតនៅឃុំស្ពោ ឃុំចំរើន និងឃុំមេធម ស្រុកសង្គមថ្មី និង ស្រុករវៀង ខេត្តព្រះវិហារ




**សញ្ញាសំគាល់**

- ▲ ក្រៃ
- ● ទីតាំងគោល
- ព្រំប្រទល់ដី
- ផ្លូវ
- ផ្លូវលំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ឃុំ
- តំបន់ទ្រនាប់ផ្លូវទឹក ១ ១១៤ ហ.ត
- តំបន់ព្រៃរក្សាទុក ១ ៤១៧ ហ.ត

**ផ្ទៃដីពាក់ព័ន្ធប្រជាពលរដ្ឋ ២០ ហិកតា**
**ផ្ទៃដីត្រូវរក្សាទុកសរុប ២ ៥៣១ ហិកតា**
**ផ្ទៃដីវិនិយោគសរុប ៥ ៩៨០ ហិកតា**

គម្របព្រៃឈើ២០០៦

- ព្រៃស្រោង ៦៣៩ ហ.ត
- ព្រៃពាក់កណ្តាលស្រោង ១ ១៣៥ ហ.ត
- ព្រៃល្បោះ ៦ ៨៦៤ ហ.ត
- ព្រៃរបោង១ ៥៦៥ ហ.ត
- ដីគ្មានគំរបព្រៃ ១២៩ ហ.ត

**ផ្ទៃដីស្នើសុំសរុប ៨ ៩៣០ ហិកតា**

Coordinate System
Projection UTM
Zone 48
Grid 1 Km
Horizontal Datum Indian 1960
Spheroid Everest
មាត្រដ្ឋាន ១ : ៧០ ០០០
0 0.5 1 2
Kilometers

---

លេខ..267......
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
ស្ពោ, ថ្ងៃទី29ខែ11ឆ្នាំ២០១១
មេឃុំ
ឆែម_ស៊ុន

លេខ308/11ខម
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
ចំរើន, ថ្ងៃទី29ខែ11ឆ្នាំ២០១១
មេឃុំ
សោម_សុខុម

លេខ...457/11
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
មេធម, ថ្ងៃទី29ខែ11ឆ្នាំ២០១១
មេឃុំ

លេខ.................
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
សង្គមថ្មី, ថ្ងៃទី29ខែ11ឆ្នាំ២០១១
ប្រធានភូមិបាលស្រុក

លេខ023/11
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
រវៀង, ថ្ងៃទី29ខែ11 ឆ្នាំ២០១១
ប្រធានភូមិបាលស្រុក
នុច_រិទ្ធី

លេខ.082........
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
រវៀង, ថ្ងៃទី29ខែ11ឆ្នាំ២០១១
ការិយាល័យកសិកម្មស្រុក

លេខ.1ឲ/11....
បានឃើញ និងឯកភាព
បញ្ជូនមក លោកអភិបាលស្រុក ពិនិត្យសម្រេច
សង្គមថ្មី, ថ្ងៃទី15ខែ11 ឆ្នាំ២០១១
ការិយាល័យកសិកម្មស្រុក
ហ៊ី ហាច់

លេខ..105........
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច
សង្គមថ្មី, ថ្ងៃទី 27ខែ11 ឆ្នាំ២០១១
អភិបាលស្រុក
វ៉ស_ហេង

លេខ484ព.ជរ
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច
រវៀង, ថ្ងៃទី29ខែ11 ឆ្នាំ២០១១
អភិបាលស្រុក
ឈួយសារ៉ូ

លេខ123.ឃស្ត.៣៧
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច
ព្រះវិហារ, ថ្ងៃទី30ខែ11 ឆ្នាំ២០១១
ប្រធានមន្ទីរបរិស្ថានខេត្ត
ខួយ_ឃុនចន្ធ័ត្ន

លេខ 351
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច
ព្រះវិហារ, ថ្ងៃទី 30ខែ11 ឆ្នាំ២០១១
ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត
គួច_សោភ័ណ

លេខ...
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេច
ព្រះវិហារ, ថ្ងៃទី..ខែ12 ឆ្នាំ២០១១
ប្រធានមន្ទីរកសិកម្មខេត្ត
ពឹង.ត្រឹង

លេខ1756.ចអរ.ផ
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យសម្រេច
ព្រះវិហារ, ថ្ងៃទី..ខែ 12 ឆ្នាំ២០១១
អភិបាលខេត្ត
ស៊ំ ម៉ាក់